ពត៌មានសំខាន់ចេញកម្មវិធីម៉ាសហិល
Important Message about Your MassHealth Benefit

ចំពោះអស់លោក-លោកស្រីដែលទទួលជំនួយចេញថ្លៃព្យាបាលពីក្រសួង ម៉ាសហិល អស់លោក-លោកស្រីប្រហែលជាបានទទួលលិខិតពីក្រសួងនេះ ស្តីអំពីជំនួយថ្មីៗដែលចាប់មានប្រសិទ្ធភាពកាលពីថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 2006 កន្លងទៅនេះ។

ដោយយោលទៅតាមច្បាប់រដ្ឋ ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2006 ទៅ កម្មវិធីម៉ាសហិលនឹងផ្តល់ជំនួយថែមទៀតដល់អ្នកដែលមានអាយុ ពី 21 ឆ្នាំ ឡើងទៅ។ ពី មុនមកកម្មវិធីម៉ាហិល បានផ្តល់ជំនួយប្រភេទនេះ ដល់អ្នកដែលមានអាយុក្រោម 21 រួចទៅហើយ។

មនុស្សពេញវ័យដែលទទួលជំនួយម៉ាសហិលស្ថិនដា, ជំនួយនៅពេលមានផ្ទៃពោះ, កំមិលហិល, បេស៊ិក, និង ជំនួយសំរាប់អ្នកមានផ្ទុកមេរោគ HIV អាចទទួលជំនួយ ដូចតទៅនេះបន្ថែមទៀត។

- ជំនួយចេញថ្លៃពេទ្យធ្មេញ: មាន ដូចជា ពិនិត្យទូទៅ (Check up) លាងធ្មេញ (Cleaning), ប៉ះធ្មេញ (Filling), ដកឬស, និង ធ្មេញ denture ឬធ្មេញដាក់។ ជំនួយទាំងនេះខ្លះ ត្រូវការយល់ព្រមពីម៉ាសហិលជាមុនសិន។ ចំពោះបញ្ជីរាយឈ្មោះគ្រូពេទ្យធ្មេញដែល ទទួលយកម៉ាសហីល សូមមេត្តាអាច វិសៃរបស់ម្រសួងម៉ាសហិល www.mass.gov/masshealth/dentist ។
- ជំនួយចេញថ្លៃពេទ្យភ្នែក: មានដូចជាចេញថ្លៃវ៉ែនតា, ភ្នែកដាក់ (Contact lense) , និង ប្រដាប់មើលដូចជា កែវពង្រីកជាដើម។ ម៉ាសហិលនៅតែចេញថ្លៃពិនិត្យមើលភ្នែកដូចពីមុនដដែល។
- ជំនួយចេញថ្លៃពេទ្យធ្វើសរសៃ ហៅថា Chiropractice ។
- ជំនួយចេញថ្លៃប្រដាប់សំរាប់ស៊កទ្រាប់ក្នុងស្បែកជើង ជាពិសេសចំពោះអ្នកជម្ងឺទឹកនោមផ្អែម ក៏អាចទទួលជំនួយចេញថ្លៃប្រដាប់ស្បែកជើងនេះបានដែរ។
- ជំនួយចេញថ្លៃប្រដាប់អវយវៈ ដូចជាប្រដាប់តដៃនិងជើងជាដើម
- ឥឡូវនេះ ម៉ាសហិលអាចជួយបង់ថ្លៃពេទ្យសំរាប់អ្នកជម្ងឺដែលមានបញ្ហាញៀនសុរានិងគ្រឿងញៀនឯទៀត ទៅតាមក៏រិតនៃវិធីព្យាបាលអនុមតិដោយក្រសួងសាធារណៈសុខាភិបាលនៃរដ្ឋម៉ាសាឈូសេត្ស។
- ជំនួយចេញថ្លៃចាត់ចែងការនៅពេលលោកអ្នកសំរាន្តក្នុងមន្ទីរពេទ្យ

បន្ថែមពីលើជំនួយទាំងប៉ុន្មានដែលខ្ញុំបាទបានអធិប្បាយមកនេះ ចាប់ពីថ្ងៃទី 1 ខែកក្កដានេះទៅ កម្មវិធីម៉ាសហិលនឹងជួយចេញថ្លៃសំរាប់លោកអ្នកក្នុងការព្យាបាល;ជាមួយកម្មវិធីជួយផ្តាច់ការទទួលទានបារីដល់អ្នកទទួលជំនួយម៉ាសហិលស្តិនដា, ជំនួយនៅពេលមានផ្ទៃពោះ, កំមិលហិល, បេស៊ិក, និង ជំនួយសំរាប់អ្នកមានផ្ទុកមេរោគ HIV គ្រប់វ័យទាំងអស់។ សមាជិកអាចទទួលជំនួយចេញថ្លៃការផ្តលឧវាទជាក្រុមឬសំរាប់ម្នាក់ឯងផ្តល់។ កម្មវិធីជំនួយនេះសំរាប់ចេញថ្លៃឲ្យគ្រូពេទ្យ, មណ្ឌលសុខភាព, និងមន្ទីរពេទ្យ ដែលទទួលយកថ្លៃពីកម្មវិធីម៉ាសហិល។

មនុស្សពេញវ័យដែលទទួលជំនួយម៉ាសហិលអេសសិនឆែល (Essential) អាចទទួលជំនួយទាំងប៉ុន្មានដែលខ្ញុំបាទអធិប្បាយអម្បាញមិញដែរ លើកលែងតែ ជំនួយថ្លៃពេទ្យភ្នែក, ពេទ្យធ្មេញ, និងពេទ្យខាងប្រដាប់តដៃជើង។

ចំពោះពត៌មានបន្ថែម អស់លោក-លោកស្រីអាចទូរស័ព្ទទៅ ក្រសួងម៉ាសហិល លេខ 1-800-841-2900 ឬអានវិបសៃ អស័យដ្ឋាន [www.mass.gov/masshealth](http://www.mass.gov/masshealth) ។ ពេលម៉ោងធ្វើការ គឺពីថ្ងៃ ច័ន្ទ ដល់ថ្ងៃសុក្រ, ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច។

ចំពោះអស់លោក-លោកស្រីដែលអញ្ជើញទៅព្យាបាលជម្ងឺនៅមណ្ឌលមេត្តាសុខាភាព អស់លោក-លោកស្រីអាចអញ្ជើញទូរស័ព្ទទៅ មណ្ឌលមេត្តាសុខភាព នៃមណ្ឌលសុខភាពសហាគមន៍ក្រុងឡូវែល លេខ (978) 441-1700 បាន។